Khmer/Cambodian

EQUITY IN EDUCATION
COALITION

# ពត៌មានស្តីពីការហាមដេញអ្នកជួលផ្ទះ

**ការហាមដេញនេះនឹងបន្តរហូតដល់ខែតុលាទី១៥។**

នៅថ្ងៃទី 29 ខែកុម្ភះឆ្នាំ 2020 លោកអភិបាលរដ្ឋ Inslee បានចេញសេចក្តីប្រកាសលេខ 20-55 ដោយប្រកាស អំពីភាពអាសន្នសម្រាប់តំបន់ទាំងអស់នៅទូទាំងរដ្ឋវ៉ាស៊ីនតោនដែលជាលទ្ធផលនៃការឆ្លងជំងឺខូរ៉ូណាឆ្នាំ 2019 (COVID-19) នៅសហរដ្ឋអាមេរិកនិងមានការបញ្ជាក់អោយឃើញមានការឆ្លងជំងឺខូវីដ១៩ COVID-19 ពីមនុស្ស ម្នាក់ទៅមនុស្សទៀតនៅក្នុងរដ្ឋវ៉ាស៊ីនតោន។

ការផ្អាកដេញអ្នកជួលផ្ទះជាបណ្តោះអាសន្ននិងសកម្មភាពដែលពាក់ព័ន្ធទូទាំងរដ្ឋវ៉ាស៊ីនតោនជួយកាត់បន្ថយភាពលំបាក ផ្នែកសេដ្ឋកិច្ច, ជីវិតរស់នៅ, សុខភាព និងហានិភ័យសុវត្ថិភាពដល់សមាជិកនៃកម្លាំងពលកម្មរបស់យើងដែលរងគ្រោះដោយសារការបាត់បង់ការងារនិងការកាត់បន្ថយម៉ោងធ្វើការយ៉ាងច្រើនធ្វើអោយពួកគេមិនអាចបង់ថ្លៃជួលផ្ទះដែលបណ្តាលមកពីជំងឺខូវីដ-១៩ COVID-19 ។

ជាក់ស្តែងណាស់ ការផ្អាកដេញអ្នកជួលផ្ទះជាបណ្តោះអាសន្នហើយនិងសកម្មភាពដែលពាក់ព័ន្ធ នឹង (1) ជួយកាត់បន្ថយ អស្ថិរភាពលំនៅដ្ឋាន (2) ជួយឱ្យប្រជាជនអាចស្នាក់នៅក្នុងផ្ទះរបស់ខ្លួន លើកលែងតែ ត្រូវធ្វើការងារចាំបាច់ឬទៅធ្វើការ បម្រើអាជីវកម្មចាំបាច់ និង (3) លើកកម្ពស់សុខភាពសាធារណៈនិងសុវត្ថិភាព ដោយជួយកាត់បន្ថយការរាលដាលជំងឺខូ  វីដ-១៩ COVID-19 នៅក្នុងរដ្ឋវ៉ាស៊ីនតោន។នេះគឺជាការប្រកាសជាផ្លូវការពីការិយាល័យរបស់លោកអភិបាលរដ្ឋ

ចំណុចសំខាន់ៗដែលត្រូវកត់សំគាល់៖

EQUITY IN EDUCATION COALITION

ចំណុចសំខាន់ៗដែលត្រូវកត់សំគាល់៖

1. ការផ្អាកបណ្តេញជាបណ្តោះអាសន្ននេះមិនមែនមានន័យថា អ្នកមិនចាំបាច់បង់ថ្លៃជួលផ្ទះនោះទេ។ នៅក្រោមច្បាប់ផ្អាក បណ្តេញជាបណ្តោះអាសន្ន, ម្ចាស់ផ្ទះមិនអាចតំឡើងថ្លៃជួលផ្ទះបានទេ ហើយគេ សង្ឃឹមថា ម្ចាស់ផ្ទះនឹងមានផែនការ អោយអ្នកជួលផ្ទះសងថ្លៃជំពាក់តាមក្រោយ។ នៅក្រោមច្បាប់ផ្អាកបណ្តេញជាបណ្តោះអាសន្ននេះ ម្ចាស់ផ្ទះក៏មិនអាចគិតថ្លៃ ពិន័យបង់យឺតពេលដែរ។ គេនៅអាចដេញអ្នកជួលផ្ទះចេញបានដោយមានហេតុផលផ្សេងៗទៀត ដូចជា ការធ្វើអោយខូច ខាតទ្រព្យសម្បត្តិឬប្រព្រឹត្តបទឧក្រិដ្ឋ។
2. សេចក្តីប្រកាសដែលលោក Inslee បានចុះហត្ថលេខា ក៏ហាមធ្វើការសងសឹកដល់អ្នកជួលផ្ទះនិងដាក់ពាក្យប្តឹងអ្នក ជួលផ្ទះ។
3. គេមិនអាចដេញអ្នកចេញពីផ្ទះបានទេក្នុងអំឡុងពេលមានវិបត្តិ លើកលែងតែអ្នកបង្កការគំរាមកំហែងដល់ម្ចាស់ផ្ទះឬម្ចាស់ ផ្ទះរបស់អ្នកចង់ដាក់ផ្ទះលក់ឬចង់ចូលមកនៅផ្ទះនោះ។
4. ប្រសិនបើម្ចាស់ផ្ទះរបស់អ្នករំលោភលើបទបញ្ជានេះ សូមដាក់ពាក្យបណ្តឹងទៅការិយាល័យរដ្ឋអាជ្ញានៃ រដ្ឋវ៉ាស៊ីនតោន។
5. អ្នកអាចប្រើលិខិតនេះជាគំរូ ផ្ញើទៅម្ចាស់ផ្ទះរបស់អ្នកប្រសិនបើគេផ្ញើសំបុត្រមកទារថ្លៃជួលផ្ទះឬដេញអោយអ្នកចេញពីផ្ទះ ជួល។ អ្នកអាចប្រើលក្ខខណ្ឌច្បាប់កែប្រែខសន្យាជួលផ្ទះអំឡុងកើតជំងឺខូវីដ-១៩ COVID-19 ដើម្បីជួយអ្នកប្រើវាជាវិធីចរចារជាមួយម្ចាស់ផ្ទះរបស់អ្នក។
6. មានធនធានជាច្រើនសម្រាប់ផ្តល់ជំនួយហិរញ្ញវត្ថុដែលទាក់ទងនិងជំងឺខូវីដ១៩។